

# ជេនីលីនឈប់អូសអេក្រង់ទូរស័ព្ទហើយ

*នាងពិតជាចង់មើលវីដេអូបន្ទាប់ខ្លាំងណាស់ ។ ហើយវីដេអូបន្ទាប់ទៀត ។ ហើយវីដេអូបន្ទាប់ទៀត ។*

ដោយ ឆាលលុត ឡាខាបាល ស្ពីកមេន
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅប្រទេសម៉ាឡេស៊ី ។*

ជេនីលីនបានអូសម្រាមដៃរបស់នាងកាត់អេក្រង់ទូរស័ព្ទ ។ វីដេអូបានលោតបង្ហាញ ។ នាងបានឈប់ដើម្បីមើលរឿងមួយ បន្ទាប់មកអូសតទៅទៀត ។ បន្ទាប់មកនាងបានបន្តមើលវីដេអូមួយផ្សេងទៀត ។ វាមានភាសាអាក្រក់ជាច្រើន ប៉ុន្តែវាគួរឲ្យអស់សំណើច ដូច្នេះនាងបានបន្តមើល ។ ហើយបន្ទាប់មកបានបន្តអូសទៅទៀត ។

« ជេនីលីន ! ចង់មកគូររូបទេ ? » ប្អូនស្រីរបស់នាង ចូចូ បានលើកក្រដាសមួយសន្លឹកគ្រវី ។

ជេនីលីនបានសម្លឹងមើល ។ « ចាំបន្តិចទៀត » ។

« ចាស » ។ ចូចូ មានមុខស្រពោន ហើយបានដាក់ក្រដាសចុះ ។

*អូស ។ អូស ។ អូស ។* វីដេអូរបស់សត្វគួរឲ្យស្រឡាញ់ ។ វីដេអូរបស់មនុស្សល្បីៗ ។ វីដេអូរបស់កុមាររាំ ។ ហើយជេនីលីនបានដឹងថាមានវីដេអូពីរបីមិនគួរមើលទេ ។ ការពិតទៅប្រហែលជាច្រើនជាងពីរបីវីដេអូ ។ ជេនីលីនបានចាប់ផ្តើមមានអារម្មណ៍ថានាងគួរតែឈប់មើលវីដេអូទាំងនោះ ។

នាងបានគិតថា *ប៉ុន្តែ មនុស្សក៏ចុះផ្សាយរឿងល្អៗផងដែរ* ។ នាងថែមទាំងបានរៀនពីរបៀបគូរថ្មីៗមកពីវីដេអូមួយចំនួនផងដែរ ។

« ជេនីលីន » ម៉ាក់ហៅ ។

« អឺមម ? » ជេនីលីនមិនខ្វីសូម្បីតែសម្លឹងមើលលើកនេះ ។

ម្តាយបាននិយាយថា « យើងមានបាយឆាគ្រឿងសមុទ្រនៅយប់នេះ » ។ តើកូនអាចជួយម៉ាក់ធ្វើវាបានទេ ?

ជេនីលីនចូលចិត្តបាយឆាគ្រឿងសមុទ្រណាស់ ។ ប៉ុន្តែ នាងមិនចង់ក្រោកឡើងទេឥឡូវនេះ ។

នាងបានសួរថា « តើកូនគ្រាន់តែរៀបតុបានទេ ? » « កូនក៏អាចជួយលាងចានក្រោយញ៉ាំហើយផងដែរ » ។

ម៉ាក់បានឆ្លើយថា « អីចឹងក៏បាន »។ « ប៉ុន្តែកូនត្រូវរៀបវាឲ្យបានត្រឹមត្រូវនៅពេលម៉ាក់ប្រើ ។ បន្ទាប់មកវាដល់ពេលហុចទូរស័ព្ទមកវិញ ។ ព្រមទេ ? »

ជេនីលីន បាននិយាយថា « ព្រម » ។

ជេនេលីនបានបន្តមើលវីដេអូតទៅទៀត ។ ជាថ្មីម្តងទៀតនាងមានអារម្មណ៍ថានាងមិនគួរមើលវាទេ ។ ប៉ុន្តែនាងពិតជាចង់មើលវីដេអូមួយទៀតណាស់ ។ ហើយវីដេអូបន្ទាប់ទៀត ។ ហើយវីដេអូបន្ទាប់ទៀត ។ *អូស ។ អូស ។* វាពិបាកបញ្ឈប់ណាស់ !

ចុងក្រោយជេនីលីនបានដាក់ទូរស័ព្ទចុះ ។ ប្រហែលជានាងអាចមើលវីដេអូមួយចុងក្រោយឲ្យចប់សិន . . . .

*អត់ទេ* ជេនីលីន ប្រាប់ខ្លួនឯងយ៉ាងម៉ឺងម៉ាត់ ។ ព្រះវិញ្ញាណបរិសុទ្ធបានបំផុសគំនិតដល់នាង ហើយនាងចង់ស្តាប់តាម ។ ដៃរបស់នាងនៅតែក្បែរទូរស័ព្ទ ។ វាល្បួងខ្លាំងណាស់ ! ជេនីលីនបានប្រឹងបិទភ្នែករបស់នាង ។

*ព្រះវរបិតាសួគ៌ដ៏ជាទីស្រឡាញ់* នាងបានអធិស្ឋានដោយស្ងៀមស្ងាត់ ។ *កូនខំព្យាយាមស្តាប់តាមព្រះវិញ្ញាណបរិសុទ្ធ កូនត្រូវការជំនួយ ។ កូនចង់ឈប់មើលវីដេអូទាំងអស់នេះ តែកូនមិនប្រាកដថាត្រូវធ្វើយ៉ាងម៉េចទេ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។*

ភ្លាមនោះ ម៉ាក់ក៏បានហៅនាងឲ្យរៀបតុ ។ ជេនីលីនបានក្រោកឡើងហើយញញឹម ។ នេះគឺជាវិធីមួយដើម្បីជួយនាងឲ្យឈប់មើលទូរសព្ទ ។

ជេនីលីនបានរៀបចាននៅលើតុ ។ « ម៉ាក់ ខ្ញុំបានឃើញ រឿងអាក្រក់ខ្លះនៅលើទូរស័ព្ទ » នាងបានភ្លាត់មាត់និយាយចេញមក ។

ម៉ាក់ងើបមុខឡើងពីការធ្វើម្ហូបរបស់គាត់ ។ « តើរឿងបែបណា ? »

« ដូចជាពាក្យអាក្រក់ៗ និងវីដេអូមិនល្អអីណឹង » ។ ជេនីលីនបានញាក់ស្មា ។ « ប៉ុន្តែវាមិនមែនជារឿងអាក្រក់ *ទាំងអស់* នោះទេ » ។

« តើកូនបានធ្វើអ្វីនៅពេលឃើញរឿងអាក្រក់អីចឹង ? » ម៉ាក់ បានសួរ ។

ជេនីលីនបាននៅស្ងៀមមួយសន្ទុះ ។ នាងបានដាក់ពែងមួយនៅកន្លែងនីមួយៗ ។

នាងបាននិយាយថា « ខ្ញុំបានបន្តមើលវា » ។ ខ្ញុំអត់ដឹងថាហេតុអីទេ ។ ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធបានប្រាប់ខ្ញុំឲ្យឈប់ ដូច្នេះខ្ញុំបានពោលពាក្យអធិស្ឋានសុំជំនួយ » ។

ម្តាយបានដាក់ចានបាយឆាគ្រឿងសមុទ្រដែលក្តៅហុយនៅលើតុ ។ ម៉ាក់បាននិយាយថា « ពេលខ្លះវាពិតជាពិបាកណាស់ក្នុងការឈប់ធ្វើអ្វីមួយ ទោះបីជាយើងដឹងថាវាមិនល្អក៏ដោយ » ។ « ហើយនៅពេលដែលរឿងនោះកើតឡើង ការណ៍ដែលល្អបំផុតដែលយើងអាចធ្វើបាននោះគឺអធិស្ឋាន » ។

ជេនីលីនបានញញឹម ។ « អីចឹងខ្ញុំបានធ្វើអ្វីមួយត្រឹមត្រូវ » ។

« កូនពិតជាធ្វើបានល្អណាស់ » ។ ម៉ាក់បានហុចស្លាបព្រាទៅឲ្យជេនីលីនដាក់នៅលើតុ ។ « ហើយអ៊ីនធឺណែតមិនអាក្រក់ទាំងអស់ទេ ។ វាអាចជួយយើងឲ្យទាក់ទងជាមួយមិត្តភក្តិ និងចែកចាយគំនិតយោបល់ ។ ប៉ុន្តែវាអាចពិបាកនៅក្នុងការនៅឲ្យឆ្ងាយពីរឿងអាក្រក់ទាំងអស់ផងដែរ ។ ពីពេលនេះទៅបើកូនមើលវីដេអូ យើងមើលវាជាមួយគ្នា ។ ធ្វើបែបនេះប៉ា និងម៉ាក់អាចជួយបាន ប្រសិនបើកូនឃើញអ្វីមួយមិនល្អ » ។

ជេនីលីនបានងក់ក្បាល ។ លើកក្រោយមកនាងបានមើលវីដេអូជាមួយម៉ាក់ និងប៉ា ។ ប៉ុន្តែទំរាំដល់ពេលនោះ មានរឿងសប្បាយជាច្រើនដែលនាងអាចធ្វើបានដោយគ្មានទូរស័ព្ទ ។

« តើកូនប្រាប់អ្នករាល់គ្នាថាវាដល់ពេលញ៉ាំអាហារពេលល្ងាចហើយ បានទេ ? » ម៉ាក់បានសួរ ។

« ចាស ! ពេលញ៉ាំអាហារពេលល្ងាចហើយ ខ្ញុំនឹងគូររូបជាមួយចូចូ ! » ●

